# ជំងឺទូទៅ
# សុខភាពបឋម



កម្មវិធីគ្លីនិក

អង្គការថែទាំសុខភាពគ្រួសារកម្ពុជា រ៉ាក់

# សិទ្ធិរបស់អតិថិជនដែលមកទទួលសេវា នៅគ្លីនិក "រ៉ាក់" មានដូចខាងក្រោម :

១- *សិទ្ធិក្នុងការទទួលយកព័ត៌មាន* : អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលយកព័ត៌មានស្ដីអំពីផលប្រយោជន៍នៃការពន្យារកំណើត ទីកន្លែងផ្ដល់សេវាពន្យារកំណើត និងសេវាថែទាំសុខភាពផ្លូវភេទ ។

២- *សិទ្ធិក្នុងការទទួលសេវា* : អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលសេវាពន្យារកំណើតដោយមិនគិតអំពីស្ថានភាពសង្គម សេដ្ឋកិច្ច សាសនា និន្នាការ នយោបាយ ជនជាតិ ពណ៌សម្បុរ ស្ថានភាពអាពាហ៍ពិពាហ៍ ឬទីកន្លែងស្នាក់នៅឡើយ ។

៣- *សិទ្ធិក្នុងការជ្រើសរើស* : អតិថិជនទាំងអស់មានសិទ្ធិសម្រេចចិត្តក្នុងការជ្រើសរើសប្រើប្រាស់ ឬមិនប្រើប្រាស់មធ្យោបាយពន្យារកំណើតណាមួយដោយសេរី ។

៤- *សិទ្ធិមានសុវត្ថិភាព* : អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលបាននូវសុវត្ថិភាព សុខភាពទាំងផ្លូវកាយ ទាំងផ្លូវចិត្តក្នុងការប្រើប្រាស់មធ្យោបាយពន្យារកំណើតណាមួយ ។

៥- *សិទ្ធិឯកជន* : អតិថិជនទាំងអស់មានសិទ្ធិក្នុងការពិភាក្សាតម្រូវការ ការព្យួយបារម្ភ ឬការពិនិត្យរាងកាយរបស់ពួកគេ នៅក្នុងទីកន្លែងណាដែលគេមានអារម្មណ៍កក់ក្ដៅ ។

៦- *សិទ្ធិរក្សាការសម្ងាត់* : អតិថិជនទាំងអស់គួរតែត្រូវបានធានាថារាល់ព័ត៌មានទាំងឡាយដែលគេបានប្រាប់ ឬសេវាទាំងឡាយដែលគេបានទទួលនឹងមិនត្រូវបន្តទៅអ្នកទីពទេ លើកលែងតែមាន ការយល់ព្រមពីសាម៉ីខ្លួន ។

៧- *សិទ្ធិរក្សាភាពថ្លៃថ្នូរ និងកិត្តិយស* : អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលរាក់ទាក់ដោយភាពគួរសម ការយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្ន និងការគោរពដោយភាពថ្លៃថ្នូរ ដោយមិនប្រកាន់នូវចំណេះដឹង ស្ថានភាពសង្គម ឬឋានន្តរសក្តិឡើយ ។

៨- *សិទ្ធិមានផាសុកភាព* : អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលសេវាកម្មដែលមានលក្ខណៈផាសុកភាពដោយអារម្មណ៍ពេញចិត្តពេញថ្លើម ។

៩- *សិទ្ធិក្នុងការបន្ត* : អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលសេវាកម្ម និងមធ្យោបាយពន្យារកំណើតបានយូរទៅតាមសេចក្ដីត្រូវការរបស់ពួកគេ ។

១០-*សិទ្ធិក្នុងការបញ្ចេញមតិយោបល់* : អតិថិជនទាំងអស់មានសិទ្ធិក្នុងការបញ្ចេញយោបល់ និងទស្សនៈ អំពីការផ្ដល់សេវាកម្មដែលពួកគេបានទទួល ។



គ្លីនិក រ៉ាក់ មានវេជ្ជបណ្ឌិត និងគ្រូពេទ្យប្រុសនិងស្ត្រី ដែលមានជំនាញនិងបទពិសោធន៍ខ្ពស់ រង់ចាំទទួលព្យាបាល លោកអ្នកតាមបច្ចេកទេសវេជ្ជសាស្ត្រយ៉ាងត្រឹមត្រូវ ។



សេវាប្រកបដោយគុណភាព
សុវត្ថិភាពអតិថិជន
គោរព និងស្និទ្ធស្នាល
លាក់ការសម្ងាត់

# សេវានៅគ្លីនិក "រ៉ាក់"

មានទទួលពិនិត្យ និងព្យាបាលជំងឺទូទៅ មនុស្សចាស់ និង កុមារ ដូចជា : ជំងឺលើសឈាម ទឹកនោមផ្អែម គ្រុនចាញ់ គ្រុនឈាម សើស្បែក ផ្លូវចិត្ត សន្លាក់ ត្រចៀក ច្រមុះ បំពង់ក ភ្នែក សួត ក្រពះ ពោះវៀន រាក តម្រងនោម ...។













# ឈឺក្បាល

ឈឺក្បាលគឺបណ្ដាលមកពីមានការប៉ះពាល់ដល់រាងកាយ ឬ សរសៃប្រសាទខួរក្បាល ដូចជា :

- ការប៉ះទង្គិចដោយគ្រោះថ្នាក់ថ្មីៗ ឬធ្លាប់មានប្រវត្តិប៉ះទង្គិច
- ការញៀនជាតិស្រវឹង
- បរិយាកាសតឹងតែង
- ការប៉ះពាល់ខួរក្បាលដោយមេរោគ
- ការករោគ

ផ្សេងទៀត



បើអ្នកឈឺក្បាលត្រូវតែទៅជួបគ្រូពេទ្យនៅគ្លីនិក រ៉ាក់ ឬទៅមន្ទីរពេទ្យដើម្បីពិនិត្យរកមូលហេតុឲ្យច្បាស់លាស់ ទើបអាចព្យាបាលជាសះស្បើយ ។

# ជំងឺរាក

ជំងឺរាកគឺជាការបញ្ចេញលាមករាវ ឬទន់ ខុសធម្មតា ចាប់ពី២ ឬ ៣ដងឡើងទៅក្នុងរយៈពេល២៤ម៉ោង ។ (ចំពោះទារកដែល ចិញ្ចឹមដោយទឹកដោះ ការបញ្ចេញលាមកទន់ជាញឹកញាប់ គេមិនរាប់ថាជាជំងឺរាកទេ ។

មូលហេតុនៃជំងឺរាក ៖

- ការខ្វះអនាម័យចំណីអាហារ
- ការប្រើទឹកមិនស្អាត និងដៃក្រខ្វក់ នៅពេលរាក អ្នកជំងឺបាត់បង់ជាតិទឹក និងជាតិអំបិលពីសារពាង្គកាយ ហើយអាចបណ្តាលឲ្យមានការខ្សោះជាតិទឹក។ ក្នុងអំឡុងពេលនោះ អ្នកជំងឺរាកមិនស្រេកឃ្លានទេ ដូច្នេះត្រូវ បន្តឲ្យផឹកទឹក និងញ៉ាំចំណីអាហារនៅពេលរាក ។

*ពេលមានរាក ត្រូវប្រញាប់ទៅគ្លីនិក រ៉ាក់ ឬ មន្ទីរពេទ្យ ជាបន្ទាន់ដើម្បីពិនិត្យ និងព្យាបាល ព្រោះអ្នកជំងឺអាចស្លាប់ដោយសារការខ្វះជាតិទឹក និងអាហារូបត្ថម្ភ (សុខភាពចុះខ្សោយ ។*

# គ្រុនក្ដៅ

១- គ្រុនក្ដៅគឺជាការកើនឡើងកំដៅលើសពី៣៧អង្សា នៅពេល ព្រឹក និងលើសពី៣៧.៣អង្សា នៅពេលល្ងាច ។ គ្រុនក្ដៅមាន រោគសញ្ញាផ្សេងរួមផ្សំទៀតដូចជា :



- បែកញើស
- ក្រហមស្បែក
- ឈឺចាប់សាច់ដុំ និងមិនស្រួលខ្លួនទូទៅ

២- <u>ទំនាក់ទំនងជាមួយគ្រុនក្ដៅ</u> :

- គ្រុនក្ដៅដែលឈានទៅរកគ្រុនចាញ់គឺគ្រុនក្ដៅខ្លាំងក្លា ញាក់ បែកញើស ឈឺក្បាល ស្មារតីទ្រុឌទ្រោម
- គ្រុនក្ដៅដែលអាចឈានទៅរកជំងឺគ្រុនពោះវៀន
- គ្រុនក្ដៅឈានទៅរកជំងឺគ្រុនឈាម
- គ្រុនក្ដៅបណ្ដាលមកពីមានជំងឺផ្សេងៗដូចជា រលាកបំពង់ក រលាកត្រចៀក រលាកដៃស្បូន រលាកទងសួតៗលៗ

*បើមានគ្រុនក្ដៅ សូមនាំអ្នកជំងឺទៅគ្លីនិក រ៉ាក់ ឬ មន្ទីរពេទ្យពិនិត្យរកមូលហេតុ ដើម្បីព្យាបាលឲ្យត្រូវ ប្រភេទជំងឺនោះទើបជាសះស្បើយ ។*

# ជំងឺផ្តាសាយ

របៀបចម្លង : ជំងឺផ្តាសាយឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់តាមផ្លូវដង្ហើម (ពេលក្អក កណ្តាស់ ។

រោគសញ្ញា : ជាទូទៅច្រើនកើតឡើងភ្លាមៗដែលជារួមមាន :



- គ្រុនក្តៅ ក្អកគ្មានឈាម
- ឈឺក្បាល ហៀរសំបោរ
- ឈឺសាច់ដុំ ឈឺសន្លាក់
- ឈឺបំពង់ក ល្វិតល្វៃទូទៅ

ការព្យាបាល :

- ទទួលទានអាហារឲ្យបានគ្រប់គ្រាន់

និងបង្កើនការសម្រាក

- ផឹកទឹកឲ្យច្រើន
- ប្រើថ្នាំប៉ារ៉ាសេតាមុល ដើម្បីជួយបញ្ចុះកំដៅបន្ថយការឈឺចាប់

*ចំណាំ : ត្រូវព្យាបាលទៅតាមរោគសញ្ញា ប្រសិនបើការព្យាបាលមិនបានធូរស្រាល ឬមានអាការៈធ្ងន់ធ្ងរជាងមុន ត្រូវប្រញាប់ទៅគ្លីនិក រ៉ាក់ ឬមន្ទីរពេទ្យដើម្បីពិនិត្យ និងព្យាបាលជាបន្ទាន់ ។*

# ជំងឺរលាកផ្លូវដង្ហើម

*ជំងឺរលាកផ្លូវដង្ហើមរួមមាន :*

- រលាកច្រមុះ
- រលាកបំពង់ក
- រលាកទងសួត
- រលាកសួត
- ហើមសួត



*រោគសញ្ញា :*

- ក្អកស្ងួត ឬមានស្លេស
- ហត់ ដកដង្ហើមញាប់ៗ
- ដកដង្ហើមចូលមានផតនៅចន្លោះឆ្អឹងជំនី
- ក្តៅខ្លួន ឡេវៈឡេវៈ
- មិនឃ្លានអាហារ

*ផលវិបាក :*

- កំណកឈាមក្នុងសួតដែលបណ្តាលឲ្យមានបញ្ហាបេះដូង
- មហារីកទងសួត និងសួត
- ករណីធ្ងន់ធ្ងរអាចបណ្តាលឲ្យស្លាប់ (ក្អកធ្លាក់ឈាម និងថប់ដង្ហើម

# ជំងឺភ្នែកក្រហម

ជំងឺភ្នែកមានច្រើនសណ្ឋានណាស់   ដូចជា :

១–   ជំងឺភ្នែកក្រហម (ជំងឺរលាកសន្ទានភ្នែក

២–   ជំងឺត្រាក់កូម

៣–   ជំងឺកង្វះជីវជាតិអា

៤–   ភ្នែកដុះកន្ទុយថ្លែន

៥–   ជំងឺឡើងបាយភ្នែក

៦–   ការរលាកភ្នែកនឹងជាតិគីមី

៧–   ជំងឺដំបៅត្របកភ្នែក

៨–   ជំងឺរលាកប្រស្រីភ្នែក និងជំងឺរលាកអ៊ុយវ៉េ

៩–   ជំងឺគ្លោកូមស្រួចស្រាវ

១០–របួសភ្នែក



*ជំងឺកង្វះជីវជាតិអា*

*ការបង្ការជំងឺភ្នែក :*

- កុំយកដៃមិនស្អាតញីភ្នែក
- ត្រូវលាងសម្អាតភ្នែកដោយទឹកសម្រាប់លាងភ្នែក
- ត្រូវមានអនាម័យក្នុងការរស់នៅ



*រាល់ជំងឺដែលមាននៅលើភ្នែក ត្រូវប្រញាប់ទៅព្យាបាល ជាបន្ទាន់ នៅគ្លីនិក រ៉ាក់ ឬនៅមន្ទីរពេទ្យ ព្រោះភ្នែកសំខាន់ណាស់សម្រាប់ជីវិតរស់នៅរបស់អ្នក ។*

# ជំងឺរលាកប្លោកនោម

ជាការករោគនៅប្លោកនោម និងនៅផ្លូវបង្ហូរនោម ។ ជំងឺនេះ ច្រើនកើតញឹកញាប់នៅលើមនុស្សស្រី និងកុមារី។

*មូលហេតុ :*

- កើតឡើងដោយសារការសុងចំពោះបុរសហើយកើតឡើងដោយសារការករោគនៅទ្វារមាសចំពោះស្ត្រី។

រោគសញ្ញា :

- នោមឈឺ
- នោមញឹក
- ទឹកនោមឡើងល្អក់ និងជួនកាលមានឈាម
- គ្មានគ្រុនក្តៅ

**ចំណាំ :** *បើសិនជាមានតែនោមឈឺមួយមុខក៏ដោយ ត្រូវប្រញាប់ទៅព្យាបាលភ្លាមនៅគ្លីនិក រ៉ាក់ ឬមន្ទីរពេទ្យ ព្រោះមានជំងឺដទៃជាច្រើនទៀតដែលទាក់ទងនឹងទឹកនោម ដូចជា : គ្រួសក្នុងប្លោកនោម ដុំនៅក្នុងប្លោកនោម រលាកឬមហារីកប្រូស្តាត របេងផ្លូវបន្តពូជ រលាកទ្វារមាស ត្បៀតរន្ធនោម វិបត្តិសរសៃប្រាសាទ ខ្សោយតម្រងនោម ។ល។*

# ជំងឺបណ្ដាលមកពីពពួកព្រូន

ជំងឺមួយចំនួនកើតឡើងដោយសារព្រូន ហើយបណ្ដាលឲ្យមាន កង្វះអាហារូបត្ថម្ភ និងប្រភេទព្រូនខ្លះអាចធ្វើឲ្យស្លាប់បាន ។



ព្រូនមានច្រើនប្រភេទ :

*១-ព្រូនសំប៉ែត ឬតេញ៉ា :*

រស់នៅក្នុងពោះវៀន មានរាងសំប៉ែតកង់ៗ មានប្រវែង២៥ទៅ ៤០ម៉ែត្រ ។

*ការចម្លង :* ឆ្លងតាមរយៈការបរិភោគសាច់ឆៅ ។

*រោគសញ្ញា :* ជារឿយៗគ្មានរោគសញ្ញាទេ ។ ប៉ុន្តែក្នុងករណីមានរោគសញ្ញា គឺមានកំណាត់កង់ៗរបស់តេញ៉ាធ្លាក់មកតាមលាមក។ ក្រៅពីនេះ អ្នកកើតតេញ៉ាអាចមានរោគសញ្ញាផ្សេងទៀត ដូចជា: មិនឃ្លាន ឈឺពោះ រាកឬទល់លាមក អស់កម្លាំង ឈឺក្បាល វិលមុខ គេងមិនលក់ ញ័រទ្រូង ឡេះឡះ រមាស់ស្បែកកន្ទាលត្រអាក ។

*ផលវិបាក :*

- មានជំងឺលើភ្នែក ស្រវាំងភ្នែក
- ឈឺក្បាល វិលមុខ និងឆ្កួតជ្រូក

## ២-ព្រូនចង្កឹះ :

មានរាងមូល មានពណ៌ស ឬផ្កាឈូក និងមានប្រវែងពី២០ ទៅ៣០ សង់ទីម៉ែត្រ ។ កូនព្រូនអាចចូលក្នុងថ្លើម សួត បំពង់ខ្យល់ ហើយខ្លះចូលក្នុងពោះវៀនតូចវិញ ។ ក្នុងរយៈពេល ៦០ថ្ងៃ វានឹងក្លាយជាព្រូនពេញវ័យ។

*ការចម្លង :*



- ឆ្លងតាមទឹក ឬតាមម្ហូបអាហារមិនស្អាត

*រោគសញ្ញា :*

- ក្នុងដំណាក់កាលដំបូង : មានក្អកហាត់ កំហាកមានស្លេស
- ដំណាក់កាលបន្ទាប់ : ក្អួតចង្អោរ ឈឺពោះ រាក ចេញកន្ទាលត្រអាក មានសំលេងតាមសួត ។ ព្រូនអាចចូលដល់ខួរក្បាល តម្រងនោម ភ្នែក ខួរឆ្អឹងខ្នង ។

ផលវិបាក : បង្កឲ្យស្ទះពោះវៀនតូច ។

ប្រសិនបើព្រូនចូលទៅ ក្នុងថង់ទឹកប្រម៉ាត់ បង្កឲ្យចុកក្រោមឆ្អឹងជំនីរខាងស្ដាំ រលាក ថង់ទឹកប្រម៉ាត់ រលាកស្រោមពោះ ឬធ្លាយថ្មេរពោះវៀន បន្ទាប់ពីវះកាត់ ។

## ៣-ព្រូនអង់គីឡូស្តូម :

ជាព្រូនពណ៌សមានប្រវែង ៨ទៅ១៥ម៉ែត្រ វារស់នៅក្នុងដើមពោះវៀនតូចដោយភ្ជាប់ខ្លួនទៅនឹងភ្នាសពោះវៀន។ វាស៊ីឈាម ជាអាហារពី ០.០២មីលីលីត្រ ទៅ០.២ មីលីលីត្រក្នុងមួយថ្ងៃ ។ វាអាចរស់នៅក្នុងខ្លួនមនុស្សពី៤ទៅ១៥ឆ្នាំ ។



*ការចម្លង :* តាមរយៈស្បែកដែលប៉ះពាល់ដីដែលមានលាមក និងអង់គីឡូស្តូមរស់នៅ ។

*រោគសញ្ញា :*

- ដំណាក់កាលដំបូង: រលាកស្បែកជាកន្ទួលពងទឹក ឬរលាក ស្បែកក្រហមរមាស់នៅកន្លែង ដែលព្រូនចូល។ បើព្រូនចូលសួតបណ្តាលឲ្យក្អកមានស្លេសស្អកក ។
- ដំណាក់កាលបន្ទាប់ : ឈឺចុងដង្ហើម មិនឃ្លាន រាកក្អួត ចង្អោរ ។

*ផលវិបាក :* បើព្រូនមាននៅក្នុងខ្លួនយូរទៅវានឹងបណ្តាលឲ្យស្លេកស្លាំង អស់កម្លាំង ហត់ បេះដូងដើរញាប់សម្ពាធឈាមចុះបេះដូងរីកធំ ថ្លើមរីកធំ ហើម ។

## ៨-អៀន :

អៀនជាព្រូនតូចពណ៌ស មានប្រវែង១សង់ទីម៉ែត្រ ។ បន្ទាប់ ពីបង្កកំណើត អៀនញីធ្វើដំណើរទៅទ្វារលាមក ដែលនៅទីនោះ វាបញ្ចេញពងនៅពេលយប់ ។ នៅមជ្ឈដ្ឋានខាងក្រៅ ពងអៀន ញាស់ក្លាយជាកូនអៀន ដែលអាចចម្លងបាន ។ នៅក្នុងពោះវៀន កូនអៀនធំធាត់ ហើយវិវត្តន៍ទៅជាអៀនពេញវ័យក្នុងរយៈពេល៣អាទិត្យ។

*ការចម្លង :*

ឆ្លងតាមរយៈដៃក្រខ្វក់និងតាមក្រចកដែលមានពងអៀន។

*រោគសញ្ញា :*

- រមាស់គូថពេលយប់
- ដេកមិនលក់ ដេកមិនស្កប់ រសាប់រសល់
- ចំពោះស្ត្រីអាចឲ្យរមាស់ផ្លូវភេទ

## ៥-ព្រូនអង់គីលុល :

ជាព្រូនតូចប្រវែង ២–៣មីលីម៉ែត្រ វារស់នៅផ្តុំគ្នាក្នុងភ្នាសដើមពោះវៀនតូច ។

*ការចម្លង :*

ឆ្លងតាមរយៈស្បែក តាមការប៉ះពាល់ដីដែលមាន លាមក និងព្រូនអង់គីលុល ។

*រោគសញ្ញា :*

៣០ភាគរយគ្មានរោគសញ្ញាទេ ។ ក្នុងដំណាក់កាលដំបូងមានលេចឡើងនូវសញ្ញារមាស់ស្បែកត្រង់កន្លែងព្រូនចូល ។ សញ្ញាបន្ទាប់បន្សំរួមមាន ហត់ ក្អក ក្អកស្លេស ។ ដំណាក់កាល បន្ទាប់ ឈឺចុងដង្ហើមក្រោយទទួលទានអាហារ រាក ទល់លាមក ។

*ផលវិបាក :*

ករណីព្រូនច្រើនបណ្តាលឲ្យចេញកន្ទាលត្រអាករលាកស្បែក និងសញ្ញាប៉ះពាល់ដល់ខួរក្បាល (ស្លាប់ ។

## ៦-ព្រូន ទ ស៊ីស្តូហ្សូមីញ៉ា :

ជាដង្កូវតូចម្យ៉ាង ចេញពីខ្យងដែលរស់នៅកន្លែងមានថ្ម ក្នុងទឹក។

*ការចម្លង :* ចម្លងមកមនុស្សតាមរយៈស្បែកក្នុងពេលដែលមនុស្សងូតនៅក្នុងទឹកទន្លេ ឬ បឹង ស្ទឹងដែលមានថ្ម ។ ជាពិសេស នៅរដូវក្តៅចាប់ពីខែមិនា ដល់ខែមិថុនា ។

*រោគសញ្ញា :* មនុស្សខ្លះមានព្រូននេះនៅក្នុងខ្លួន តែមិនមានចេញរោគសញ្ញាអ្វីឡើយ។ ជំងឺព្រូនទដែលមានចេញទម្រង់ស្រួចស្រាវ ចាប់ពី២ទៅ៦អាទិត្យក្រោយឆ្លងគឺ :

- គ្រុនក្តៅ
- កន្ទាលត្រអាក ឈឺសន្លាក់ និងសាច់ដុំ
- ឡើងហើមហើយឆាប់ស្រកវិញ
- ក្អក និងហត់ ឈឺក្បាល ឈឺពោះ រាក នោមឈាម

*<u>ដំណាក់កាលរ៉ាំរ៉ៃ</u> :*

- ថ្លើមរីកធំ ធ្លាក់អណ្តើក ស្លេកស្លាំង ពោះធំ
- លាមកសំបោរឈាម

*ផលវិបាក :* ធ្លាយសរសៃឈាម ធ្លាយរន្ធបង្ហូរនោម ដុំក្នុងប្លោកនោម ចុកថ្លើម រលាកសាច់ដុំបេះដូង ឆ្អួតជ្រួក ។

### វិធីការពារពីការចម្លងព្រូន :

- លាងដៃឲ្យស្អាត
- កាត់ក្រចកឲ្យខ្លី
- ផឹកទឹកឆ្អិន
- លាងបន្លែ ផ្លែឈើឲ្យស្អាត
- ការពារកុំឲ្យរុយទុំលើម្ហូបអាហារ
- បត់ជើងក្នុងបង្គន់
- ត្រូវពាក់ស្បែកជើង កុំដើរជើងទទេរ
- សាច់ត្រូវចម្អិនឲ្យឆ្អិនមុនទទួលទាន

### ការព្យាបាល :

បើសិនជាមានឃើញរោគសញ្ញាដូចបានរៀបរាប់ខាងលើ ត្រូវទៅ គ្លីនិក រ៉ាក់ ឬមន្ទីរពេទ្យដើម្បីពិនិត្យលាមក ឬពិនិត្យ ឈាមតាមការព្យាបាលរបស់គ្រូពេទ្យ និងត្រូវលេបថ្នាំឲ្យទៀងទាត់តាមវេជ្ជបញ្ជារបស់គ្រូពេទ្យ ។

# ការពុលចំណីអាហារ

ការពុលអាហារបង្កឡើងដោយសារ ៖

– ការបរិភោគអាហារដែលមានការឆ្លងរោគដូចជាបាក់តេរី
វីរុស និងប៉ារ៉ាស៊ីត ។

– ការបរិភោគជាតិពុល និងជាតិគីមី ។



*រោគសញ្ញា ៖*

– ចង្អោរ
– ក្អួត
– រាក
– ឈឺពោះ
– ចុកពោះ
– មិនឃ្លានបាយ
– អស់កម្លាំង
– ក្តៅខ្លួន

*រោគសញ្ញាអាចកើតមានក្នុងអំឡុងប៉ុន្មានម៉ោងបន្ទាប់ពីបរិភោគចំណីអាហារដែលមានមេរោគ ឬប៉ុន្មានថ្ងៃក្រោយមក ។ បើសង្ស័យថាមានពុលចំណីអាហារ ត្រូវប្រញាប់នាំអ្នកជំងឺទៅគ្លីនិក រ៉ាក់ ឬមន្ទីរពេទ្យព្យាបាលជាបន្ទាន់ ។*

# អាប់សៃ

អាប់សៃគឺជាកំណាខ្ទុះក្នុងសាច់ទន់នៅក្នុងចន្លោះមួយដែលឱសថថ្នាំផ្សះមិនអាចជ្រាបចូលបាន ។



អាប់សៃមានដូចជា :

- អាប់សៃដោះ
- អាប់សៃ ក
- អាប់សៃនៅក្រលៀន
- អាប់សៃនៅជិតសរសៃអាទែរធំៗ

*រោគសញ្ញា :*

- ហើម ក្រហម ឈឺនៅលើស្បែក
- មាន ឬគ្មានគ្រុន

*ការព្យាបាល :*

អ្នកមិនអាចព្យាបាលដោយប្រើថ្នាំបង្ក្រាប ឬថ្នាំផ្សះបានទេ បើមានសភាពបែបនេះ ត្រូវទៅគ្លីនិក រ៉ាក់ ឬមន្ទីរពេទ្យ ដើម្បីព្យាបាលជាបន្ទាន់ ។

## សេវានៅគ្លីនិក "រ៉ាក់"

១– ពន្យារកំណើត (ថ្នាំលេប ថ្នាំចាក់ កងដាក់ដៃ កងដាក់ក្នុងស្បូន ស្រោមអនាម័យ បញ្ឈប់កំណើត រហូត (ចងដៃស្បូន និងចងបំពង់មេជីវិតបុរស

២– ពិនិត្យ និងព្យាបាលជំងឺទូទៅ (មនុស្សចាស់–កុមារ

៣– ថែទាំផ្ទៃពោះមុនសម្រាលនិងសុខភាពក្រោយសម្រាល

៤– ពិនិត្យ និងព្យាបាលជំងឺកាមរោគ (បុរស–ស្ត្រី

៥– វិភាគកោសិកាមាត់ស្បូនរកមើលជំងឺមហារីកមាត់ស្បូន

៦– ព្យាបាលដុតមាត់ស្បូនដោយឧបករណ៍ទំនើប

៧– ពិនិត្យ និងព្យាបាលសុខភាពបន្តពូជស្ត្រី និងបុរស

៨– សេវាថែទាំ និងគាំទ្រស្ត្រីត្រូវគេរំលោភ

៩– មន្ទីរពិសោធន៍វេជ្ជសាស្ត្រ

១០– ផ្តល់ប្រឹក្សា និងពិនិត្យឈាមរកមេរោគអេដស៍

១១– ផ្តល់ប្រឹក្សាអំពីសុខភាពបន្តពូជបុរស–ស្ត្រីមុនរៀបការ

១២– ព្យាបាល និងថែទាំក្រោយរលូតកូន

១៣– ព្យាបាល និងផ្តល់ប្រឹក្សាការមិនមានកូន

១៤– វះកាត់តូច

១៥– ចាក់ថ្នាំការពារតេតាណូស ថ្លើមប្រភេទវីរុសបេ និង វ៉ាក់សាំងការពារមហារីកមាត់ស្បូន

១៦– ពិនិត្យអេកូសាស្ត្រ

# អាសយដ្ឋានគ្លីនិក " រ៉ាក់ "

## រាជធានីភ្នំពេញ

**គ្លីនិកភ្នំពេញ១** : ( មានសេវាពិនិត្យ **MSM** )
ផ្ទះលេខ៦ ផ្លូវលេខ១៩០ ស.វាលវង់
ខណ្ឌ៧មករា ទូរស័ព្ទ : ០២៣-៨៨១ ៦២១

**គ្លីនិកភ្នំពេញ២** : ( មានសេវាពិនិត្យ **MSM** )
ផ្ទះលេខ៣៨-៤០ ផ្លូវលេខ៤៣២ ស.ទួលទំពូង១
ខណ្ឌចំការមន ទូរស័ព្ទ : ០២៣-២១៨ ៥០៤

**គ្លីនិកស្ទឹងមានជ័យ** : ( មានសេវាពិនិត្យ **MSM** )
ផ្ទះលេខ ១៩. ២០. ២១ ភូមិត្រពាំងថ្លឹង
ស.ចោមចៅ ខណ្ឌដង្កោ
ទូរស័ព្ទ : ០២៣-៩៨៥ ៧៧៣

**គ្លីនិកចាក់អង្រែក្រោម** :( មានសេវាពិនិត្យ **MSM** )
ផ្ទះលេខ ១៦០៧ ភូមិទួលរកា
ស.ចាក់អង្រែក្រោម ខណ្ឌមានជ័យ
ទូរស័ព្ទ : ០២៤-៩៨៥ ០៧៩

**គ្លីនិកទួលសង្កែ / មណ្ឌលយុវវ័យ**:( មានសេវាពិនិត្យMSM)
ផ្ទះលេខ ១៦២៤ ផ្លូវជាតិលេខ៥ ភូមិឃ្លាំងសាំង
ក្រុម៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ
ទូរស័ព្ទ :០២៣-៩៩០ ៧៧៣

**គ្លីនិកទឹកថ្លា** : ( មានសេវាពិនិត្យ **MSM** )
ផ្ទះលេខG35-G37 ផ្លូវហ្គូដឌី
សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ
ទូរស័ព្ទ : ០២៣-៨៨៣ ០២៦

**គ្លីនិកទំនប់ថ្មី** : ( មានសេវាពិនិត្យ **MSM** )
ផ្ទះលេខ៣A+៤A ផ្លូវមុន្នីរ៉េត
ភូមិដំណាក់ធំ១ សង្កាត់ស្ទឹងមានជ័យ
ខណ្ឌមានជ័យ ទូរស័ព្ទ : ០២៣-៩៩៥ ៤៧៦

## ខេត្តបាត់ដំបង

**គ្លីនិក** :( មានសេវាពិនិត្យ **MSM** )
ផ្ទះលេខ១៥៤,៤៤៩ ភូមិព្រែកមហាទេព
ឃុំស្វាយប៉ោ ស្រុកបាត់ដំបង
ទូរស័ព្ទ : ០៥៣-៩៥២ ៦១០

## ខេត្តព្រះសីហនុ

**គ្លីនិក / មណ្ឌលយុវវ័យ**:( មានសេវាពិនិត្យ **MSM** )
ផ្ទះលេខ៥៥៥ ផ្លូវឯករាជ្យ មណ្ឌល៤ សង្កាត់៤
ខណ្ឌមិត្តភាព ទូរស័ព្ទ : ០៣៤-៩៣៣ ៩៤២

## ខេត្តកំពង់ចាម

**គ្លីនិក / មណ្ឌលយុវវ័យ**:( មានសេវាពិនិត្យ **MSM** )
ផ្ទះលេខ១០ ផ្លូវត្រសក់ផ្អែម ភូមិ១៥ ឃុំកំពង់ចាម
ស្រុកកំពង់ចាម ទូរស័ព្ទ : ០៤២-៩៤១ ៥០២

**គ្លីនិកសួង** : ( មានសេវាពិនិត្យ **MSM** )
ភូមិសួងលិច ឃុំសួង ស្រុកត្បូងឃ្មុំ
ទូរស័ព្ទ : ០១៦-៣០៦ ៩១១

## ខេត្តតាកែវ

**គ្លីនិក** : ផ្ទះលេខ៥ ផ្លូវលេខ៨ ភូមិឡូរី
សង្កាត់រការក្នុង ក្រុងដូនកែវ
ទូរស័ព្ទ : ០៣២-៩៣១ ៣៦១

## ខេត្តសៀមរាប

**គ្លីនិក / មណ្ឌលយុវវ័យ** :( មានសេវាពិនិត្យ **MSM** )
ភូមិត្រពាំងសេះ ឃុំគោកចក
ទូរស័ព្ទ : ០៦៣-៩៦៤ ៩៦០

## ខេត្តកំពង់ស្ពឺ

**គ្លីនិក / មណ្ឌលយុវវ័យ** : ( មានសេវាពិនិត្យ **MSM** )
ភូមិស្មោរទី១ សង្កាត់រកាធំ ក្រុងច្បារមន
ខេត្តកំពង់ស្ពឺ ទូរស័ព្ទ :០២៥-៩៨៧ ១៤៥

## ខេត្តស្វាយរៀង

**គ្លីនិក** : ៥០ ភូមិបាវិតកណ្តាល សង្កាត់បាវិត
ក្រុងបាវិត ទូរស័ព្ទ : ០៤៤-៩៤៦ ០៦៦

## ខេត្តកំពត

**គ្លីនិក** : ផ្ទះលេខ៥១ ផ្លូវជាតិលេខ៣៣
ភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្តាល ក្រុងកំពត
ទូរស័ព្ទ : ០៣៣ ៩៣២ ៧៦៨

សៀវភៅនេះផលិតតាមបច្ចេកទេស និងគំនិតរបស់បុគ្គលិក
អង្គការ " រ៉ាក់ " ក្រោមការឧបត្ថម្ភថវិការបស់
ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ USAID
ក្រោមគម្រោងរួមគ្នាដើម្បីសុខភាពល្អ

<u>កំណត់សម្គាល់</u>: តួអង្គនៅក្នុងសៀវភៅ គ្រាន់តែជាការសម្តែងប៉ុណ្ណោះ

បោះពុម្ពលើកទី.... ចំនួន ............... ក្បាល ឆ្នាំ២០១២

**IEC,2012**